## សាលារៀននឹងបិទទ្វាររហូតដល់ចុងឆ្នាំសិក្សា

ការបិទទ្វារសាលារៀននៅក្នុងក្រសួងអប់រំឡុងប៊ីចនឹងបន្តរហូតទៅដល់ចុងឆ្នាំសិក្សាឬដល់ថ្ងៃទី១១ខែមិថុនា ដោយសារតែការបន្តនូវជំងឺរាតត្បាតកូរ៉ូណា។ កាលពីដំបូងយើងបានគ្រោងបើកសាលាវិញនៅថ្ងៃទី៤ខែឧសភា។

" ថ្ងៃនេះយើងគួរតែមានដំណឹងល្អចែកចាយដល់លោកអ្នក " អគ្គនាយកសាលារៀនក្រសួងអប់រំឡុងប៊ីច LBUSD លោក Christopher J. Steinhauser បានមានប្រសាសន៍។ " ក៏ប៉ុន្តែ អាទិភាពខ្ពស់បំផុតរបស់យើងគឺសុខភាពនិងសុវត្ថិភាពដល់សិស្សានុសិស្សយើងនិងក្រុមគ្រួសារសិស្សហើយនិងបុគ្គលិករបស់យើង។ យើងបានធ្វើការសម្រេចចិត្តនេះដោយបានពិភាក្សាយ៉ាងល្អិតល្អន់ជាមួយអង្គការជាដៃគូផ្សេងៗ មានរួមទាំងក្រសួងសុខាភិបាលខោនធីឡូសអ៊ិនជើលេសផងដែរ"

**ដោយសារតែការបិទទ្វារសាលារៀនជាបន្តនេះ ពិធីអបអរពេលសិស្សរៀនចប់វិទ្យាល័យ graduation ceremonies នឹងមិនបានធ្វើឡើងដូចតាមការគ្រោងទុកនោះឡើយ។**

**" យើងយល់ដឹងណាស់អំពីសារៈសំខាន់ដ៏ធំធេងនៃការអបអរពិធីរៀនចប់ពីវិទ្យាល័យនេះ ហើយយើងកំពុងតែគិតគូរកមើលរបៀបធ្វើពិធីអបអរនេះតាមវិធីផ្សេងទៀត " លោក Steinhauser បានមានប្រសាសន៍បន្ត " យើងនឹងជូនដំណឹងជាបន្តបន្ទាប់ដល់សហគមន៍ឱ្យបានជ្រាប"**

នៅក្នុងពេលដែលសាលារៀននៅក្នុងក្រសួងអប់រំបិទទ្វារនេះ កម្មវិធីសិក្សានៅផ្ទះ Home Learning Opportunities នឹងបន្តដំណើរការទៅមុខដោយមានការកែសម្រួលខ្លះៗ ហើយសាលារៀននឹងបន្តផ្តល់ចែកចាយអាហារសម្រាប់កុមារនៅតាមសាលារៀនចំនួន៣៥កន្លែង។

កម្មវិធីសិក្សានៅផ្ទះ **Home Learning Opportunities**

ក្រសួងអប់រំ LBUSD បានចាប់ផ្តើមផ្តល់កម្មវិធីសិក្សានៅផ្ទះសម្រាប់សិស្សទូទៅនិងសិស្សក្នុងកម្មវិធីអប់រំពិសេសនិងក្រុមគ្រួសាររបស់គេកាលពីថ្ងៃទី២៣មិនាមក។

នៅក្នុងរយៈពេលដែលសាលាបិទទ្វារនេះ សិស្សនិងមាតាបិតាអាចចូលទៅគេហទំព័រ Home Learning Opportunities webpage ដើម្បីរកមើលធនធានពីសាលារៀនរបស់កូនគាត់។ គេហទំព័រនេះក៏មាននៅ lbschools.net/HLO ហើយជំនួយគាំទ្របច្ចេកទេសក៏មានផ្តល់ឱ្យនៅក្នុងគេហទំព័រនោះដែរ។

ដំបូង មេរៀននិងធនធានទាំងឡាយត្រូវបានបង្កើតឡើងសម្រាប់គាំទ្រការសិក្សាជាបន្តរបស់សិស្សនៅតាមកំរិតថ្នាក់របស់គេរហូតដល់ថ្ងៃទី៩មេសា (ថ្ងៃមុនថ្ងៃឈប់សម្រាក់បុណ្យ ទី១០មេសា និងសប្តាហ៍ឈប់សម្រាកនិទាឃរដូវក្នុងសប្តាហ៍បន្ទាប់) មេរៀននិងកិច្ចការរៀនពីផ្ទះទាំងនេះនឹងមិនកែឱ្យពិន្ទុជាផ្លូវការទេ។ ក៏ប៉ុន្តែ បន្ទាប់ពីថ្ងៃឈប់សម្រាកនិទាឃរដូវនៅថ្ងៃទៅ២០មេសា សិស្សនឹងត្រូវទទួលខុសត្រូវលើកិច្ចការសិក្សាដែលគ្រូដាក់ឱ្យធ្វើនិងការចូលរួមសិក្សាពីផ្ទះ។ ព័ត៌មានលំអិតនឹងមានផ្តល់ឱ្យតាមក្រោយស្តីអំពីកិច្ចការសិក្សាដែលគ្រូដាក់ឱ្យធ្វើនិងការចូលរួមសិក្សាពីផ្ទះនិងទំនួលខុសត្រូវរបស់សិស្ស។

“ គ្រូបង្រៀនរបស់យើងបានធ្វើការពីផ្ទះដើម្បីជួយបន្តការរៀនសូត្ររបស់សិស្សតាមសមត្ថិភាពដែលអាចធ្វើបាននៅក្នុងកាលៈទេសៈនេះ សម្រាប់សិស្សទាំងអស់គ្នា ”។ លោក Steinhauser បានមានប្រសាសន៍ “ ជាពិសេស យើងចង់បញ្ជាក់ថាសិស្សឆ្នាំទីបួននៅវិទ្យាល័យរបស់យើងត្រូវបានត្រៀមខ្លួនរួចរាល់សម្រាប់រៀនឱ្យបានជោគជ័យនៅសាកលវិទ្យាល័យ ”

ដើម្បីជួយគ្រួសារសិស្សឱយអាចប្រើប្រាសអ៊ិនធើនែត សាលារៀនបានផ្តល់កុំព្យូទ័រក្រុមប៊ុគ Chromebook ជិត ១០ ០០០ មួយម៉ឺនគ្រឿងកន្លងមកថ្មីៗនេះដល់សិស្សដែលត្រូវការឧបករណ៍ប្រើប្រាសនៅផ្ទះ។ នេះគឺបន្ថែមពីលើក្រុមប៊ុគចំនួន ២០០០០ គ្រឿងដែលបានផ្តល់ឱ្យសិស្ស ឱ្យទុកប្រើប្រាសនៅផ្ទះ កាលពីដើមឆ្នាំសិក្សា។ មាតាបិតា អាណាព្យាបាលដែលនៅត្រូវការខ្ចី ក្រុមប៊ុកសម្រាប់ឱ្យកូនគាត់ អាចដាក់ពេលណាត់ជួបជាមួយសាលារៀនដើម្បីដាក់ពេលមកយកក្រុមប៊ុគ។ ថែមពីនោះទៀត សាលារៀនក៏មានផ្តល់ព័ត៌មានដល់គ្រួសារអំពីរបៀបមានលទ្ធភាពប្រើប្រាសអ៊ិនធើនែតនៅផ្ទះ នឹងក្រដាសមេរៀនឬកិច្ចការសិស្ស ដែលបានផ្តិតចេញមកជាក្រដាស សម្រាប់អ្នកណាដែលត្រូវការ។

## អាហារ

LBUSD នឹងផ្តល់អាហារសម្រាប់យកទៅញ៉ាំនៅផ្ទះដល់កុមារអាយុមួយឆ្នាំដល់ ១៨ឆ្នាំនៅ ក្នុងរយៈពេលដែលសាលាបិទទ្វារនៅសាលា: Addams, Avalon, Birney, Bixby, Burbank, Chavez, Dooley, Emerson, Gant, Garfield, Gompers, Grant, Harte, Henry, Herrera, King, Lafayette, Lincoln, Lindbergh, Longfellow, MacArthur, Marshall, McKinley, Muir, Riley, Rogers, Roosevelt, Signal Hill, Smith, Stevenson, Twain, Washington, Whittier and Willard. រកមើលផែនទីសាលារៀន ដោយចូលទៅគេហទំព័រក្រសួងអប់រំនៅ lbschools.net រួចចុច ABOUT > Map ។

### ព័ត៌មានបន្ថែមទៀត

ព័ត៌មានបន្ថែមទៀតនឹងជូនដំណឹងពីសាលារៀនរបស់កូនអ្នកហើយនឹងត្រូវផ្តល់ជូនតាមវិធីច្រើនយ៉ាង ដែលមានរួមទាំងនៅតាមគេហទំព័រ lbschools.net/coronavirus, តាមគេហទំព័រសាលានីមួយៗ, តាមអ៊ីមែល សារ text, សារទូរស័ព្ទនិងតាមបណ្តាញសង្គម។ មាតាបិតាអាចធ្វើបច្ចុប្បន្នភាពព័ត៌មានសម្រាប់ឱ្យសាលាធ្វើទំនាក់ទំនងជាមួយនិងរបៀបប្រសើរជាងគេសម្រាប់ធ្វើទំនាក់ទំនងជាមួយគាត់ ដោយចូលទៅកម្មវិធី ParentVue, ដោយចុចលើពាក្យ PARENTS នៅគេហទំព័រ lbschools.net។